ការសម្ភាសរបស់លោកយាយ សូរ ផាត់

ក៖ អ្នកសម្ភាសឈ្មោះ រិទ្ធ ស៊ីនភានិច ខ៖ អ្នកត្រូវគេសម្ភាសឈ្មោះ សូរ ផាត់

ក៖ ចឹងថ្ងៃនេះ ខ្ញុំសូមអរគុណលោកយាយបន្ថែមទៀតសម្រាំការសម្ភាស ហើយចូលរួមសម្ភាសជាមួយលោកយាយចឹងណា។ ហើយខ្ញុំដឹងផងដែលថាការសម្ភាសមួយនេះនឹងជួយដល់កូនចៅរបស់លោកយាយ ដល់ចៅដូនរបស់លោកយាយទៀតអាចបានស្គាល់ប្រវត្តិរបស់លោកយាយច្រើន។ ហើយការសម្ភាសនេះបានកើតឡើងនៅក្រោយសាកលវិទ្យាល័យមួយនៅអាមេរិច ហៅកាត់ថា BYU គេបង្កើតឡើងដើម្បីជួយប្រជាជនខ្មែរឱ្យមានប្រវត្តិច្រើន ចែករំលែកទៅដល់កូនៗរបស់លោកយាយ និង ចៅលោកយាយនៅជំនាន់ក្រោយទៀតចឹងណា។ សាកលវិទ្យាល័យហ្នឹងគេហៅ BYU គេហៅឈ្មោះពេញគឺ Brigham Young University ជាសាកលវិទ្យាល័យមួយ។ ហើយការសម្ភាសមួយនេះត្រូវបានធ្វើឡើងនៅថ្ងៃទី២៤ ខែ៤ ឆ្នាំ២០១៧ ហើយសម្ភាសដោយខ្ញុំផ្ទាល់ឈ្មោះ ស៊ីនភានិច។ ចឹងលោកយាយអាចជួយប្រាប់ ពីឈ្មោះពេញរបស់លោកយាយបានដែរទេ?

ខ៖ ខ្ញុំមានឈ្មោះ សូរ ផាត់។

ក៖ លោកយាយក្រៅពីឈ្មោះ សូរ ផាត់ មានឈ្មោះហៅនៅក្នុងផ្ទះដែរទេ?

ខ៖ អត់មានទេ មានតែឈ្មោះមួយហ្នឹង។

ក៖ លោកយាយមានអាយុប៉ុន្មានហើយឆ្នាំនេះ?

ខ៖ ខ្ញុំមានអាយុ៦៩ឆ្នាំក្នុងឆ្នាំថ្មី។

ក៖ ចឹងលោកយាយមានចងចាំអំពីថ្ងៃ ខែ ឆ្នាំណើតដែរទេ?

ខ៖ ខ្ញុំបានកើតនៅថ្ងៃទី១៣ ខែ១០ ឆ្នាំ១៩៥៣។

ក៖ ចឹងលោកយាយមានស្រុកកំណើតនៅខាងណាដែរ?

ខ៖ ខ្ញុំកើតនៅភូមិជ្រៃខាងជើង ឃុំគាងសង្កែ ស្រុកសូត្រនិគម ខេត្តសៀមរាប។

ក៖ ហើយលោកយាយ មានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានបងប្អូននៅ៤នាក់ សុទ្ធតែស្រីទាំងអស់។

ក៖ លោកយាយជាកូនទីប៉ុន្មានដែរ?

ខ៖ ខ្ញុំជាកូនទី១។

ក៖ លោកយាយជាកូនបងគេបង្អស់។ ចឹងលោកយាយ អាចជួយជំរាបឈ្មោះប្អូនៗរបស់លោកយាយ ជាបន្តបន្ទាប់បានដែរទេ?

ខ៖ ប្អូនដែលនៅ៤នាក់ ទី១ឈ្មោះ ថន ទី២ ឈ្មោះ ខុន ទី៣ ឈ្មោះ ថន ទី៤ ឈ្មោះ សេន។

ក៖ ចឹងលោកយាយមានបានចាំអំពី រឿងរ៉ាវជាមួយពួកគាត់ពីក្មេងៗទេ ដោយសារលោកយាយ ជាបងគេចឹង តើលោកយាយមានទទួលបន្ទុកអ្វីនៅក្នុងក្រុមគ្រួសារ? មើលថែពួកគាត់ចឹងណា?

ខ៖ ប្អូន១ជូនមានស៊ី ជូនអត់ម្ហូបអាហារហូបចុក មិនដែលបានគ្រប់គ្រាន់ទេ ហូបព្រឹកអត់ល្ងាចហូប ល្ងាចអត់ព្រឹក។ ថែប្អូននៅផ្ទះ ចំណែកម៉ែឪគាត់ទៅរកម្ហូបអាហារចឹងទៅ នៅមើលប្អូនចឹងទៅមិនឱ្យ ពួកវាបាត់ទៅណាទេ។ ឱ្យតែប្អូនហូបឆ្អែត ល្ងាចឡើងម៉ែគាត់មកក៏ហូបទៅ រហូតមកដល់សព្វថ្ងៃ ដូចជាព្រះអង្គញ្ញែកចែកខ្លះទេដឹង ខ្ញុំដូចជាធូរខ្លួនណាស់ បានកូនធំ១ ហើយបានបងប្អូនជួយផ្តល់លិច កើតតិចតួចទៅក៏វាធូរដែរ។ វាមិនសូវជាគិតច្រើន ថ្ងៃណាមានលុយក៏បានហូបទៅ ដល់ថ្ងៃណាអត់ក៏ វាមិនសូវជាដូចមុន។ និយាយឱ្យតែសប្បាយចិត្តអស់អារម្មណ៍ខ្លាចដាច់អត់ព្រឹក អត់ល្ងាច។

ក៖ ហើយលោកយាយសម្រាប់ជីវិតដែលជូរចត់ដែលលោកយាយ ធ្លាប់បានជួបកាលពីនៅតូច១ តើ លោកយាយនៅចាំដែរទេ?

ខ៖ ខ្ញុំដូចជាមិនសូវចាំទេ។

ក៖ ហ្ន៎ងហើយ រួចចុះម្តាយរបស់លោកយាយ គាត់មានឈ្មោះអ្វីដែរ?

ខ៖ ម្តាយរបស់ខ្ញុំឈ្មោះ យ៉ាត សៀង។

ក៖ ចុះឪពុកវិញលោកយាយ?

ខ៖ ឪពុកខ្ញុំមានឈ្មោះ ស្ងរ។

ក៖ ហើយសម្រាប់ពួកគាត់ទាំង២នាក់ បានទទួលមរណៈភាពពីឆ្នាំណាដែរលោកយាយ?

ខ៖ ខ្ញុំអត់ចាំផង ខាងឪពុក គាត់ស្លាប់តាំងពីខ្ញុំនៅតូច១។

ក៖ ចុះម្តាយវិញ លោកយាយ?

ខ៖ ទាំងម្តាយ ទាំងឪពុកទាំងអស់ កូនទៅរស់នៅជាមួយគេទេ។ ឪខ្ញុំនេះនៅនឹងគេសុទ្ធហើយ នៅជាមួយម្តាយមីងជាអ្នកចិញ្ចឹម។

ក៖ សម្រាប់ពួកគាត់ គឺជាអ្នករស់នៅក្នុងស្រុកសូត្រនិគមទាំងអស់គ្នាមែនទេលោកយាយ?

ខ៖ អត់ទេ ខាងនោះខាងចង្រៃ ខាងតាខាងឪនោះគឺខាងចង្រៃ។ បើនៅខាងម្តាយរបស់ខ្ញុំនេះ គឺនៅខាងសូត្រនិគម។

ក៖ ចឹងបងប្អូនរបស់លោកយាយទាំងអស់ រស់នៅជាមួយលោកយាយ ឬមួយក៏ពួកគាត់បែកផ្ទះហើយ?

ខ៖ រស់នៅបែកគ្នាអស់ហើយ មានគ្រួសារមានកូនមានចៅនៅទីនេះមួយ នៅឯចឹងនោះមួយនៅខាងចង្រៃដែរ។

ក៖ ចឹងសំរាប់ម្តាយរបស់លោកយាយ គាត់បានប្រកបការងារអ្វីដែរ
ដើម្បីចិញ្ចឹមជីវិតកាលគាត់នៅរស់?

ខ៖ គាត់ធ្វើតែស្រែ និង ចម្ការ ហើយនិងរកត្រីរកអីផ្សេង។

ក៖ ចុះឪពុករបស់លោកយាយវិញ?

ខ៖ រកដូចតែគ្នារកជាមួយគ្នាដែរ ដូចជាខែប្រាំងគាត់គិតទៅរកត្រីរកអីដើម្បីចិញ្ចឹមកូន។

ក៖ ដើម្បីចិញ្ចឹមជីវភាពក្នុងក្រុមគ្រួសារ។ ម្តាយរបស់លោកយាយ គាត់គឺជាមនុស្សយ៉ាងម៉េចដែរ? តើគាត់កាច់ដែរទេលោកយាយ?

ខ៖ ម្តាយរបស់ខ្ញុំ គាត់អត់កាច់ផង ឪពុកខ្ញុំក៏អត់ផង។ ពួកគាត់ស្លូតទាំង២នាក់ គាត់តែងតែប្រដៅកូនឱ្យចេះរកតាមសមត្ថភាព បើយើងរកបានក៏ហូបបានទៅ។ សូម្បីតែយើងដើរទៅ ដូចថាយើញរបស់គេ យករបស់គេ គាត់ប្រដៅកូនចឹងឯង។

ក៖ គាត់ចេះណែនាំកូន។

ខ៖ ហូបដោយសារកម្លាំងរបស់យើងទៅ កូនអើយ កុំយើញគេមាន គេបានច្រើន កុំតូចចិត្តនឹងខ្លួនឯង។ កុំឆក់យករបស់គេរបស់អីវាមានទោស គាត់ប្រដៅយើងចឹង។

ក៖ ហើយលោកយាយ មានអនុស្សាវរីយ៍កាលពីលោកយាយនៅតូចៗដែរទេ?

ខ៖ ខ្ញុំអត់មានផង។

ក៖ អត់មានទេ ហើយក្រុមគ្រួសាររបស់លោកយាយ ក្រៅពីនៅក្នុងខេត្តសៀមរាប និង ប្រទេសកម្ពុជា។ ពួកគាត់មានទៅរស់នៅក្រៅខេត្ត ឬក្រៅប្រទេសកម្ពុជាដែរទេលោកយាយ?

ខ៖ ក្រៅប្រទេស?

ក៖ ពួកគាត់មានទៅប្រទេសណាដែរលោកយាយ?

ខ៖ មិនដឹងជានៅណាទេ យូរហើយភ្លេចអស់ មិនដែលមានពេលទាក់ទងគ្នាផង។ បើខាងឪវិញ ខ្ញុំមិនដែលបានទាក់ទងគ្នាទេ មិនដឹងជានៅឯណា មិនដឹងជាគ្នានេះអត់ផង បែកពីគ្នាតាំងតែពីខ្ញុំនៅតូចៗមក។

ក៖ កាលពីលោកយាយនៅក្មេង តើលោកយាយចូលចិត្តលេងអ្វីដែរ?

ខ៖ ខ្ញុំមិនដែលលេងអីទេ មានតែកិច្ចការងារផ្ទះ ឆ្នាំងចានហ្នឹង។

ក៖ ចឹងលោកយាយនៅតែក្នុងផ្ទះធ្វើជាស្ត្រីមេផ្ទះ។

ខ៖ កាលពីនៅតូចៗមានអី មានតែម៉ែឪដើរទៅបុកស្រូវ បុកអីផ្សេង តែប៉ុណ្ណោះ។

ក៖ ចឹងលោកយាយចេះបុកអំបុកដែរទេ?

ខ៖ ខ្ញុំចេះតើ ខ្ញុំបុកអំបុក បុកអីតាំងតែពីដើមមកម៉េច។ កាលសម័យដែលបែកពីប៉ុលពត រុំឆ្នាំងបាយ ឆ្នាំងអីមកអស់ហើយ រហូតមកដល់ស្រុកចាប់ផ្តើមមានឯករាជ្យមក។ តាំងពីឆ្នាំ២០០២មក ចេះតែមានបាយហូបសប្បាយចិត្តហូរហារមក គឺថាសប្បាយចិត្តតែម្តង។ មានម្ហូបមានអីស្រាប់ទៅយើងចាំតែដាំបាយខ្លួនឯងទេ ដោយសារស្រុកមានសន្តិភាព មានភាពសំបូរសប្បាយច្រើនមកដល់សព្វថ្ងៃ។

ក៖ ចឹងសម្រាប់លោកយាយ នៅក្នុងពេលសម័យសង្គ្រាមគេឱ្យលោកយាយធ្វើអ្វីខ្លះដែរ?

ខ៖ នៅសម័យដែលគេធ្វើសង្គ្រាមនោះ គេឱ្យខ្ញុំស្ទង់ដកមើលកូន ជីកប្រឡាយ ធ្វើទំនប់។

ក៖ ជីវិតរបស់លោកយាយនៅក្នុងពេលនោះ តើមានសភាពយ៉ាងម៉េចដែរ?

ខ៖ មានម៉េចទេ មានតែភាពកម្មវេទនា ហើយហូបបាយបានតិចៗចែកកូនផងអីទៀត។ ជូនកាលទៅលាយបបរហូបចឹងទៅ ជាមួយកូនត្រកូនផងទៅដាក់លាយជាមួយគ្នា ទោះយ៉ាងម៉េចក៏ត្រូវតែហូបដែរ បើថាត្រូវដាក់ដើមចេកលាយ គឺត្រូវតែដាក់ដើមចេក ចេះតែហូបទៅធ្វើម៉េចបើយើងអត់ បើយើងមិនហូបធ្វើម៉េចមានតែអត់មានកម្លាំងធ្វើការជាមួយគេទៅ។ ហើយតែធ្វើការមិនបានដឹង តែគេពិន័យយើងហើយ គេយកយើងវាយថាឱ្យយើងស្តីឱ្យយើង គេសួរថាម៉េចបានជាឯងមិនធ្វើការ មិនស្រួលថាយើងកុហកគេទៀត។ លើកទី១គេចេះតែលើកលេងឱ្យទៅ តែតើមានលើកទី២ ដឹងតែគេយកយើងទៅវាយចោលហើយ។

ក៖ លោកយាយមានដែលតតាំងនៅពេលដែលគេប្រើលោកយាយដែរទេ?

ខ៖ ខ្ញុំអត់ហ៊ានទេនៅសម័យនោះ បើសិនជាខ្ញុំតតាំងនឹងគេ ប្រហែលជាមិនរស់មកដល់សព្វថ្ងៃនេះទេ។

ក៖ ចាស! ល្អណាស់លោកយាយ។ ហើយសាមីរបស់លោកយាយ គាត់មានឈ្មោះអ្វីដែរ?

ខ៖ គាត់មានឈ្មោះ ឡែម ផុន។

ក៖ គាត់បានទទួលមរណៈភាពហើយ ឬក៏នៅរស់សព្វថ្ងៃដែរ លោកយាយ?

ខ៖ គាត់បានទទួលមរណៈភាពបាត់ទៅហើយ។

ក៖ តាំងពីកូនៗខ្ញុំនៅតូច។ ហើយសាមីរបស់លោកយាយ គាត់គឺជាមនុស្សយ៉ាងម៉េចដែរលោកយាយ?

ខ៖ គាត់ធ្វើការ ធ្វើស្រូវ ធ្វើចម្ការដូចតែគ្នាហ្នឹង គេប្រើឱ្យទៅធ្វើ ហើយកាលពីជំនាន់សង្គ្រាមគេឱ្យគាត់ធ្វើម៉ាញ(វិទ្យុ) បើកផ្សាយឱ្យដូចថាក្មេងៗធ្វើការធ្វើអី។ គាត់ក៏ទៅភ្ជួរខែអី គាត់ក៏ទៅសស្វូងដែរ ពីព្រោះគេឱ្យយើងធ្វើទៅ គាត់មិនហ៊ានមកមើលប្រពន្ធកូនទេ។ តែហ៊ានមួយថ្ងៃអត់មកធ្វើការដ្ឋានគេ ដឹងតែគេស្តីឱ្យគាត់ថាតាងងយកលេសអត់ទៅធ្វើការ តែចឹងឯង។

ក៖ លោកតាត្រូវជាសាមីរបស់លោកយាយ គាត់មានធ្លាប់ធ្វើជាទាហានដែរទេ?

ខ៖ គាត់អត់ធ្លាប់ធ្វើទាហានទេ។

ក៖ គាត់គឺជាមនុស្សឆេវឆាវដែរទេលោកយាយ?

ខ៖ គាត់មិនមែនជាមនុស្សឆេវឆាវផង។

ក៖ ចឹងគាត់ជាមនុស្សសុភាពរាបសារ ហើយលោកយាយរៀបការពីមុនសម័យប៉ុលពត ឬក៏ក្រោយហ្នឹងដែរ?

ខ៖ ខ្ញុំបានរៀបរាបពីមុនសម័យប៉ុលពត។

ក៖ លោកយាយបានរៀបការនៅក្នុងឆ្នាំណាដែរ លោកយាយនៅចាំទេ?

ខ៖ យាយដូចជាមិនចាំទេ ពីព្រោះអីវាយូរពេក។

ក៖ ហើយអាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងដោយឪពុកម្តាយ ឬក៏ជាការសម្រេចចិត្តរបស់លោកយាយទាំង២នាក់?

ខ៖ សម្រេចចិត្តរបស់យើងទាំង២នាក់ ប៉ុន្តែឪពុកម្តាយជាអ្នករៀបចំឱ្យ។

ក៖ កាលពីពេលដែលលោកតាចូលស្តីដណ្តឹងលោកយាយ តើគាត់បានជូនថ្លៃជំនួនប៉ុន្មានដែរ?

ខ៖ ខ្ញុំអត់ចាំទេ មិនដឹងជាចំនួនប៉ុន្មានផង។

ក៖ គាត់ជូនជាលុយជាស្រូវឬក៏ជាមាស?

ខ៖ គាត់បានជូនជាលុយចាយ ជាលុយមួយរយៗ លុយកាក់ហ្ន៎ង។

ក៖ លោកយាយបានជួបលោកតាដំបូងនៅកន្លែងណាដែរ?

ខ៖ ខ្ញុំជួបតាដំបូងដូចជានៅដុំដែកនេះ ដូចជាភូមិមានស្រុក។ គាត់គឺជាអ្នកធ្វើចម្ការ ឯខ្ញុំនេះនៅខាងក្រែង ប៉ុន្តែខ្ញុំកើតនៅខាងដុំដែក ជ្រៃជើងនេះ ឃុំកៀនសង្កែ ដល់ពេលឪខ្ញុំទៅធ្វើចម្ការនៅឫក្រវិល។ ពេលទៅធ្វើនៅនោះទៅ ពួកគាត់ក៏បានជួបគ្នាទៅ ដោយសារធ្វើចំការធ្វើអីជុំគ្នាទៅ។ មិនបានជាទាក់ទងអីនឹងខ្ញុំ មិនបានជានេះយ៉ាងម៉េចផង ឱ្យតែអាយុច្រើន ដូចក្មេងសម័យឥឡូវគេថាចេះស្រឡាញ់គ្នាដល់ខ្ញុំនេះអត់ចេះសោះតែម្តង។ ចាស់ៗពីដើមគាត់អត់ចេះទេ មិនដូចជាក្មេងៗឥឡូវទេ។

ក៖ លោកយាយធម្មតាធ្វើទៅតាមប្រពៃណី។

ខ៖ ហើយក្មេងនៅសម័យសព្វថ្ងៃគឺថា មិនជឿដូចជាចាស់ពីដើមទេ ចេះតែនិយាយកុហក។

ក៖ ហើយលោកយាយមានកូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានកូនចំនួន៥នាក់។

ក៖ លោកយាយអាចជួយជម្រាបឈ្មោះរបស់ពួកគាត់បានទេ?

ខ៖ បងគេនោះឈ្មោះ ឈៀន សុផល ហើយទី២ ឈ្មោះ ផល្លា ទី៣ឈ្មោះ សូផៃ ទី៤ឈ្មោះ ផល្លី ហើយសុភីជាកូនក្រោយគេ។ កូនពៅមានឈ្មោះហៅក្រៅថា សុខពៅ ចឹងទៅ ប៉ុន្តែបើតាមសំបុត្រកំណើតអី គឺសុទ្ធតែឈ្មោះផ្សេងៗ គឺថាឈ្មោះចឹងផ្សេងទៅ ឯក្នុងសំបុត្រកំណើតផ្សេងទៀតទៅ។

ក៖ ចឹងសម្រាប់ការចិញ្ចឹមកូនៗដល់ទៅ៥នាក់ លោកយាយមានភាពលំបាកដែរទេ?

ខ៖ កាលពីដើមវាពិបាកចឹញ្ចឹមកូន ប៉ុន្តែចេះតែរកចិញ្ចឹមឱ្យពួកវាធំឡើងទៅ ដល់ពេលបានប្តីបានប្រពន្ធទៅវាដូចជារាងធូរតិច។ កាលពីទើបតែឈប់សង្គ្រាមមក ហើយឆ្នាំងចានកាលជំនាន់នោះអត់មានអ្នកប្រមូលមកទេ។ គឺថាពេលដែលញ៉ុំបបរថ្ងៃឡើង គេរៀបចំហើយគេក៏គោះជួនហៅយើងទៅ។ បើមីបងគេបង្គស់នោះ គិតតែពីអង្គុយយំ ដោយសារវាឃើញមានបន្ទែច្រើនហើយអង្ករតែមួយគ្រាប់ៗ វាអង្គុយយំតែឯងអាណិតកូនណាស់ ប៉ុន្តែមិនដឹងជាធ្វើយ៉ាងម៉េច មានតែប្រាប់កូនថា កូនអើយចេះតែហូបៗទៅ មិនដឹងជាថ្ងៃណា ឆ្នាំណាដែលផុតពីសង្គ្រាមទៅ គឺកូនបានបាយហូបដូចធម្មតាវិញហើយ។

ក៖ ចឹងមកដល់សព្វថ្ងៃ លោកយាយមានជីវភាពរីកចម្រើនជាងមុន?

ខ៖ ជីវភាពធូរស្រាល បន្ទាប់ពីបែកប៉ុលពត។ កាលនៅជំនាន់នោះមានអ្នកខ្លះគេហ៊ានទៅយកស្រូវមកទុកនៅក្នុងផ្ទះរបស់គេទៅ តែមកដល់ខ្ញុំនេះប្តីក៏មិនហ៊ាន ប្រពន្ធក៏មិនហ៊ានអត់មានទេ ពីព្រោះគេមកពីធ្វើស្រែហើយដល់ពេលដែលខែវស្សាឡើង និយាយថាវេទនានោះ កូនវាទឹកភ្នែកផង ធ្វើការផងខំទៅធ្វើការឱ្យគេដើម្បីបានអង្ករមួយគីឡូ ពីរគីឡូ ក៏ដាំឱ្យកូនហូបទៅ។ យូរៗទៅក៏បាត់ឪពុកទៀត ទុកឱ្យកូនៗនៅតែផ្ទះ មីបងជាអ្នកមើលថែបងប្អូន តើឪវាអត់ទៅដឹងតែអត់បាយទៀតហើយ។

ក៖ លោកយាយទាក់ទងនឹងភាសាវ៉ៀ ក្រៅពីភាសាខ្មែរ តើលោកយាយមានចេះភាសាអ្វីផ្សេងទៀតទេ?

ខ៖ ខ្ញុំអត់ចេះផង និយយាអក្សរខ្ញុំអត់ចេះផង ខ្ញុំអត់មានបានទៅរៀនអីទេ ទៅនៅតាមតែព្រៃតាមតែស្រុកហ្នឹង។

ក៖ លោកយាយកាលពីនៅតូចៗ លោកយាយបានរៀនត្រឹមថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ខ្ញុំអត់ដែលបានរៀនសោះតែម្តង។

ក៖ លោកយាយមានមិត្តភក្តិជិតស្និតទេ ដែលបានធំធាត់មកជាមួយគ្នា?

ខ៖ ខ្ញុំមានតែម្តាយមីង។

ក៖ ហើយលោកយាយ ក្រៅពីធ្វើស្រែចម្ការ តើលោកយាយមានធ្វើអ្វីផ្សេងទៀតទេ?

ខ៖ អត់មានធ្វើអី មានតែធ្វើនំអន្សមលក់តិចតួច។

ក៖ ហើយសំរាប់មុខម្ហូបវិញ តើលោកយាយចូលចិត្តមុខម្ហូបអ្វីដែរ?

ខ៖ ខ្ញុំចូលចិត្តតែម្ហូបស្រៃ។

ក៖ ជាម្ហូបខ្មែរយើងណោះ។ ចុះសម្រាប់ចម្រៀងវិញ លោកយាយចូលចិត្តចម្រៀងអ្វីដែរ?

ខ៖ ខ្ញុំមិនដឹងជាចូលចិត្តចម្រៀងអីទេ ខ្ញុំចូលចិត្តតែមើលគេលេងល្ខោន ដូចជាល្ខោនបាសាក់។

ក៖ លោកយាយចូលចិត្តមើលដូចខ្ញុំដែរ។ ចុះសម្រាប់ក្រុមគ្រួសាររបស់លោកយាយ តើមានអ្នកណាដែលចេះលេងភ្លេងខ្មែរដែរទេ?

ខ៖ អត់មានផង។

ក៖ ដូចជាការធ្វើម្ហូប តើលោកយាយចេះធ្វើតាំងពីអាយុប៉ុន្មានដែរ?

ខ៖ ខ្ញុំចេះធ្វើម្ហូបតាំងពីនៅក្មេងម្ល៉េះ ពេលម៉ែទៅធ្វើការក៏នៅផ្ទះមើលប្អូន ហើយក៏ធ្វើម្ហូបទៅ។

ក៖ ចឹងសម្រាប់ជីវិតរបស់លោកយាយ កាលពីមុនរហូតមកដល់ឥឡូវមានការផ្លាស់ប្តូរច្រើនដែរទេ?

ខ៖ មានការផ្លាស់ប្តូរតិចតួច។

ក៖ ពីពិបាកមកជាលក្ខណៈមធ្យមវិញ ចឹងសម្រាប់លោកយាយ តើលោកយាយមានជំនាញផ្ទាល់ខ្លួនរបស់លោកយាយដែរទេ? ដូចជាការធ្វើស្លឹកត្នោត? ជាដំបូលផ្ទះ? ការដេរប៉ាក់? ការបុកស្រូវ? ការបុកអង្ករ? ឬក៏ជាជំនាញធ្វើស្ករត្នោតអី លោកយាយមានដែរទេ?

ខ៖ ពីមុនៗមាន។

ក៖ អាចធ្វើទៅបាន ដូចជាការដែលនៅក្មេងៗ តើលោកយាយធ្លាប់មានអារម្មណ៍ថាធំឡើងចង់ធ្វើអ្វីដែរទេ?

ខ៖ វាមិនមានអារម្មណ៍ចង់ធ្វើអ្វីទេ គ្រាន់តែចង់ធ្វើចម្ការស្រែមានតែប៉ុណ្ណឹង។

ក៖ ហើយខ្ញុំដូចជាអត់មានអ្វីច្រើនដើម្បីសួរលោកយាយ តែខ្ញុំគ្រាន់តែចង់ឱ្យលោកយាយផ្តាំពាក្យចុងក្រោយ ទៅកាន់កូនចៅរបស់លោកយាយនៅជំនាន់ក្រោយ។ បើលោកយាយចង់លើកទឹកចិត្តពួកគាត់សម្រាប់ការរៀនសូត្រ ការប្រកបមុខរបរនៅក្នុងជីវិតរបស់គាត់ លោកយាយអាចនិយាយបាន។

ខ៖ ខ្ញុំសព្វថ្ងៃតែងប្រដៅកូនៗឱ្យទៅរៀនសូត្រ ឱ្យបានចេះដឹង កុំឱ្យលង់ដូចខ្ញុំពីមុន។ ធ្វើយ៉ាងម៉េចជម្រុញកូនឱ្យបានចេះដឹងថាផ្លូវណាអាក្រក់ ផ្លូវណាល្អ ហើយផ្លូវណាដែលអាក្រក់កុំទៅ។

ក៖ ចឹងលោកយាយខ្ញុំសូមអរគុណសម្រាប់ការសម្ភាសនៅក្នុងថ្ងៃនេះ។ បន្ទាប់ពីការសម្ភាសមួយនេះចប់ ប្រហែលជាមួយខែក្រោយ ពួកខ្ញុំនឹងចេញជាឌីសមួយជូនដល់លោកយាយសម្រាប់ស្តាប់។ ហើយថាកូនចៅរបស់លោកយាយក៏អាចចូលទៅក្នុងវេបសាយ ដើម្បីស្តាប់អំពីជីវប្រវត្តិរបស់លោកយាយថា លោកយាយធ្លាប់ឆ្លងកាត់អ្វីខ្លះផងដែរ។ ចឹងការសម្ភាសមួយក៏បានចប់ ហើយខ្ញុំចង់សួរទៅកាន់លោកយាយថា តើខ្ញុំអាចសុំការអនុញ្ញាតដើម្បីដាក់សម្លេងនេះទៅក្នុងវេបសាយរបស់សាលាបានដែរទេ?

ខ៖ ចាស! បានអត់អីទេ។

ក៏ ចឹង ខ្ញុំសូមអរគុណលោកយាយម្តងទៀត។